# ទិសដៅ និងសកម្មភាពអនុវត្តបន្ត
# ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍

## អង្គសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២២

**ថ្ងៃព្រហស្បតិ៍ ១ កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦**
**ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២**
**សណ្ឋាគារ វីនីណាប៊ូទិក ខេត្តព្រះសីហនុ**

បង្ហាញដោយ **វេជ្ជបណ្ឌិត ទេព ណារុធ**
**ប្រធាននាយកដ្ឋាន ផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ**

# ទិសដៅ និងសកម្មភាពអនុវត្តបន្ត (១)

| ល.រ | ទិសដៅ និងសកម្មភាពចម្បងៗ | ស្ថាប័ន ទទួលខុសត្រូវ |
|---|---|---|
| ១ | -រៀបចំគោលនយោបាយបញ្ចប់អេដស៍ និងនិរន្តរភាពនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ | NAA, MoEF, MoH, CoM ), Others |
| ២ | បញ្ចប់បច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយនិរន្តរភាពនៅកម្ពុជា (Updated HIV Sustainability Roadmap in Cambodia) | NAA, NCHADS (MoH), UNAIDS, Others |
| ៣ | រៀបចំផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៦ សម្រាប់ឆ្នាំ ២០២៤-២០២៨ ឈានទៅការបញ្ចប់អេដស៍ និងនិរន្តរភាពនៃការឆ្លើយតបមេរោគអេដស៍ នៅកម្ពុជា (National Strategic Plan on HIV Elimination and Sustainability Response in Cambodia) | NAA, MoEF, MoH (NCHADS), UNAIDS, LHSS/USAID, Others |
| ៤ | រៀបចំប្រព័ន្ធជាតិស្តីពីការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅប្រទេសកម្ពុជា (Country System for HIV and AIDS response) | NAA, MoEF, MoH (NCHADS), UNAIDS, LHSS/USAID, Others |
| ៥ | សម្របសម្រួលធ្វើបច្ចុប្បន្នភាព AIDS Epidemic Model 2023 ដោយប្រើប្រាស់នូវទិន្នន័យ ឆ្នាំ២០២២ ។ | NCHADS, NAA, UNAIDS, Others |

# ទិសដៅ និងសកម្មភាពអនុវត្តបន្ត (២)

| ល.រ | ទិសដៅ និងសកម្មភាពចម្បងៗ | ស្ថាប័ន ទទួលខុសត្រូវ |
|---|---|---|
| ៦ | -រៀបចំធ្វើបច្ចុប្បន្នភាព Optima និងដើម្បីប្រើប្រាស់ជាឧបករណ៍សម្រាប់ស្វែងរកការគាំទ្រការវិភាជន៍ថវិកាឱ្យបានសមស្រប និងបានចំទិសដៅ និងកាន់តែមានប្រសិទ្ធភាព | NAA, NCHADS (MoH), UNAIDS, Others |
| ៧ | -បញ្ចប់ការពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្ដីពីការបង្ការមេរោគអេដស៍ កាមរោគ និងការព្យាបាល ក្នុងវិស័យសុខាភិបាល (Midterm Review of National Strategic Plan for HIV/AIDS and STI Prevention and Care in Health Sector) | NCHADS (MoH), Others |
| ៨ | -បន្តកៀរគរហិរញ្ញប្បទានក្នុងស្រុក និងក្រៅស្រុក និងកំណត់អាទិភាពសកម្មភាពសម្រាប់ពង្រឹងប្រព័ន្ធជាតិ (Country System) ដើម្បីចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។<br>-សម្របសម្រួលសំណើរគម្រោងឆ្លើយតបមេរោគអេដស៍ សម្រាប់មូលនិធិសកល GF 2024-2026 | NCHADS, NAA, UNAIDS, KHANA, RHAC, Others |
| ៩ | -បន្តជំរុញអនុវត្តលិខិតលេខ ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ អំពីការដាក់វិធានការទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ដោយបន្តចុះបណ្តុះបណ្ដាលការត្រួតពិនិត្យការអនុវត្តសជណ២១៣ នៅរាជធានី និងបណ្ដាខេត្តគោលដៅ។ | NAA, Relevant ministries, Provinces |
| ១០ | បន្តកិច្ចខិតខំប្រឹងប្រែងលើការងារកិច្ចសន្យាសង្គមក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា (Social contracting on HIV and AIDS in Cambodia) និងការជំរុញការផ្តល់ប័ណ្ណសមធម៌ដល់អ្នកផ្ទុកមេរោគអេដស៍ ។ | NAA, MoEF, MoP, NCHADS/MoH, UNAIDS, LHSS, Others |

# ទិសដៅ និងសកម្មភាពអនុវត្តបន្ត(៣)

| ល.រ | ទិសដៅ និងសកម្មភាពចម្បងៗ | ស្ថាប័ន ទទួលខុសត្រូវ |
|---|---|---|
| ១១ | -បន្តការងារសម្របសម្រួលក្រុមការងារយុទ្ធសាស្ត្រថ្នាក់ជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីបន្តការអនុវត្តផែនការយុទ្ធសាស្ត្រជាតិលើកទី៥ និងការរៀបចំផែនការយុទ្ធសាស្ត្របន្តទៀតឆ្ពោះទៅបញ្ចប់អេដស៍ឆ្នាំ២០២៥។ | NAA, NSP Strategic TWG |
| ១២ | -បន្តសម្របសម្រួលក្រុមការងារ ត្រួតពិនិត្យ វាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣ ដែលស្ថិតក្រោមក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើរតួនាទីចម្បងក្នុងការប្រមូលព័ត៌មាន ពិនិត្យ វាយតម្លៃ និងផ្តល់យោបល់អំពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ។ | NAA, M&E TWG |
| ១៣ | បន្តជំរុញការអនុវត្តគម្រោងទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ (Fast-Track Cities: Ending the AIDS Epidemic) នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ និងសៀមរាប។<br>សម្របសម្រួលការរៀបចំផែនការសកម្មភាពថវិកាឆ្លើយតបមេរោគអេដស៍ នៅតាមបណ្តាក្រសួង។ រៀបចំផែនការសកម្មភាពថវិកាសម្រាប់ខេត្ត ១១ ផ្សេងទៀត ដោយប្រើប្រាស់ថវិកាជាតិ ៦០ លានរៀល/ខេត្ត ។ | NAA, PAC/PAS, UNAIDS, LHSS Others |
| ១៤ | បន្តជំរុញការរៀបចំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដោយបញ្ចូលសមាសភាពពាក់ព័ន្ធនានា រួមមានតំណាងអ្នកផ្ទុកមេរោគអេដស៍ និងតំណាងប្រជាជនគន្លឹះ បន្ថែមទៅក្នុងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក.)។ | NAA, MoI, PAC/PAS, Others |

# ទិសដៅ និងសកម្មភាពអនុវត្តបន្ត (៤)

| ល.រ | ទិសដៅ និងសកម្មភាពចម្បងៗ | ស្ថាប័ន ទទួលខុសត្រូវ |
|---|---|---|
| ១៥ | ជំរុញការធ្វើអន្តរាគមន៍បង្ការ ជាពិសេសលើក្រុមប្រជាជនគន្លឹះ (ការផ្សព្វផ្សាយអប់រំ, ការប្រើប្រាស់ស្រោមអនាម័យ ការធ្វើតេស្តឈាម និងការព្យាបាល, PrEP, PEP, U=U, HIVST, PNTT) | NCHADS, KHANA, RHAC, AHF, Others |
| ១៦ | ជំរុញបន្តស្វែងរក និងបញ្ចុះបញ្ចូលឱ្យអ្នកផ្ទុកមេរោគអេដស៍ប្រមាណជា១២.០០០នាក់ ឱ្យមកទទួលសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ និងទទួលការព្យាបាល។ | NCHADS, Partners |
| ១៧ | ជំរុញការផ្តល់សេវាបង្ការ ធ្វើតេស្តឈាម និងការព្យាបាលថែទាំ កាត់បន្ថយការចម្លងមេរោគអេដស៍ពីមាតាទៅទារក។ | NMCHC (MoH), Partners |
| ១៨ | ធ្វើការសិក្សាស្រាវជ្រាវស្តីពី IBBS on MSM, TG និងការប៉ាន់ប្រមាណចំនួន និងការសិក្សាពីការរួមភេទជាក្រុមលើក្រុមគោលដៅ (Research study on Chem Sex in Cambodia) | NCHADS, Others |
| ១៩ | ដំណើការត្រួតពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ នៃការអនុវត្តការផ្តល់ឱសថប្រឆាំងមេរោគអេដស៍ ដោយសហគមន៍ (Midterm Review on Community ARV Delivery) | NCHADS, KHANA, Others |
| ២០ | បន្តការងារការត្រួតពិនិត្យការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ដោយសហគមន៍ (Community Let Monitoring/CLM) | FONPAM/DFONPAM, HACC, FHI 360/EpiC, UNAIDS |

# ទិសដៅ និងសកម្មភាពអនុវត្តបន្ត (៥)

| ល.រ | ទិសដៅ និងសកម្មភាពចម្បងៗ | ស្ថាប័ន ទទួលខុសត្រូវ |
|---|---|---|
| ២១ | បន្តផ្តល់ការគាំទ្រទាំងថវិកា និងបច្ចេកទេសដល់ដំណើការរបស់បណ្តាញសហគមន៍នៃ PLHIV និង KPs និងវេទិការសហគមន៍ ហ្វុនប៉ាម និងឌីហ្វុនប៉ាម | HACC, FONPAM, DFONPAM, UNAIDS, EpIC FHI360 |
| ២២ | បន្តការងារបណ្តុះបណ្តាលស្តីពីការស្វែងរកការគាំទ្រ ដោយមានការចូលរួម និងការឆ្លើយតបផ្អែកលើភស្តុតាងដល់សហគមន៍អ្នករស់នៅជាមួយមេរោគអេដស៍ PLHIV និងក្រុមប្រជាជនគន្លឹះ | HACC, FONPAM, DFONPAM, UNAIDS, |
| ២៣ | បន្តការសម្របសម្រួលការរៀបចំសេចក្តីពន្យល់ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ HIV/AIDS ជាពិសេសការពិនិត្យរកមេរោគអេដស៍ លើអនីតិជន ។ | NAA, UNAIDS, NCHADS, Others |
| ២៤ | - បន្តសកម្មភាពឥស្សរជនឆ្នើមថ្នាក់ជាតិឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។<br>- បន្តធ្វើការអប់រំផ្សព្វផ្សាយ អំពីសុខភាពមាតា ទារក និងកុមារ ដោយមានបញ្ជ្រាបសារអប់រំផ្សព្វផ្សាយ ផ្តោតលើការទប់ស្កាត់ការចម្លងមេរោគអេដស៍ និងស្វាយពីម្តាយទៅកូនផងដែរ បន្ថែមពីលើការថែទាំសុខភាពមុន និងក្រោយសម្រាល ការថែទាំ បំប៉នទារក និងកុមារ | កាកបាទក្រហមកម្ពុជា |

# ទិសដៅ និងសកម្មភាពអនុវត្តបន្ត(៦)

| ល.រ | ទិសដៅ និងសកម្មភាពចម្បងៗ | ស្ថាប័ន ទទួលខុសត្រូវ |
|---|---|---|
| ២៥ | -បន្តអប់រំផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ដល់សិស្ស និស្សិត កម្មករ និយោជិតនៅតាមសហគ្រាស គ្រឹះស្ថាន និងគ្រឹះស្ថានសិក្សា<br>-បញ្ជ្រាបការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់អំពីអេដស៍ និងគ្រឿងញៀនតាមរយៈវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា។ | អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន<br>NACD |
| ២៦ | -បន្តអប់រំផ្សព្វផ្សាយពីការបង្ការមេរោគអេដស៍/ជំងឺអេដស៍ ជំងឺកាមរោគ ការប្រើប្រាស់ និងអត្ថប្រយោជន៍នៃស្រោមអនាម័យ ដល់នាយទាហាន ពលទាហាន។<br>-បញ្ជ្រាបតាមរយៈកម្មវិធីអប់រំបង្ការជំងឺកូវីដ-១៩ អប់រំចិត្តសាស្ត្រកងទ័ព អប់រំជំងឺគ្រុនចាញ់ អប់រំផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន អប់រំសុខភាពកងទ័ព ចូលរួមប្រជុំការងារយេនឌ័រ ព្រមទាំងកម្មវិធីផ្សេងៗទៀត | MoND, HQ ( ទីចាត់ការសុខាភិបាលអគ្គបញ្ជាការ ) |
| ២៧ | -បន្តតាមដានវឌ្ឍនភាព និងពង្រឹងការអនុវត្តប្រកាស០៨៦ ប្រកាស១៩៤ និងសេចក្តីជូនដំណឹង០០៨ ដល់មន្ត្រីក្រសួង មន្ត្រីមន្ទីរ ក.ប រាជធានី ខេត្ត ម្ចាស់សហគ្រាស គ្រឹះស្ថានផ្នែកសេវាកម្សាន្ត និងអ្នកពាក់ព័ន្ធ។ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ២៨ | បន្តការផ្សព្វផ្សាយ ផ្តល់ចំណេះដឹង បញ្ហាជំងឺអេដស៍ ជូនដល់ប្រជាពលរដ្ឋ និងសាធារណជន តាមរយៈ វិទ្យុ ទូរទស្សន៍ និងចូលរួមគាំទ្រដល់សកម្មភាពឥស្សរជនធ្វើមថ្នាក់ជាតិឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។ | ក្រសួងព័ត៌មាន |

# ទិសដៅ និងសកម្មភាពអនុវត្តបន្ត (៧)

| ល.រ | ទិសដៅ និងសកម្មភាពចម្បងៗ | ស្ថាប័ន ទទួលខុសត្រូវ |
|---|---|---|
| ២៩ | - អនុវត្តផែនការសកម្មភាពជាតិស្តីពីសុខភាពសិក្សាឆ្នាំ២០២១-២០៣០ ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឆ្នាំ២០២២-២០២៦ ផែនការយុទ្ធសាស្ត្រអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយសម្រាប់យុវជនក្រៅសាលាឆ្នាំ២០២២-២០២៦<br>- បង្កើនការយល់ដឹងពីសុខភាពបន្តពូជ សុខភាពផ្លូវភេទ មេរោគអេដស៍ ជំងឺអេដស៍ និងគ្រឿងញៀនដល់យុវជនក្នុងនិងក្រៅសាលារៀន<br>- បំប៉នសមត្ថភាពគ្រូនៅតាមគ្រឹះស្ថានចំណេះទូទៅ គ្រូឧទ្ទេសនាមនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងគ្រឹះស្ថានឧត្តមសិក្សាដើម្បីអប់រំបន្តដល់សិស្ស និស្សិតនៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួន និងសហគមន៍<br>- អប់រំផ្សព្វផ្សាយពីសុខភាពបន្តពូជ សុខភាពផ្លូវភេទ មេរោគអេដស៍ ជំងឺអេដស៍ និងគ្រឿងញៀនតាមរយៈវេទិកាឌីជីថលផ្លូវការរបស់ក្រសួង និងបង្កើនការផលិតខ្លឹមសារមេរៀនឌីជីថលសម្រាប់ការអប់រំ។ | ក្រសួងអប់រំ យុវជន និងកីឡា MoEYS |
| ៣០ | - ជំរុញថ្នាក់ក្រោមជាតិបន្តរៀបចំ នឹងពង្រឹងយន្តការប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្នាក់ក្រោមជាតិ រាជធានី ខេត្ត ក្រុង/ស្រុក ឃុំ/សង្កាត់ និងការរាយការណ៍មកគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍/កាមរោគ នៅខែតុលា ជារៀងរាល់ឆ្នាំ ។<br>- ជំរុញអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត បន្តកិច្ចសហការអនុវត្តសកម្មភាពទាំងឡាយដាក់ចេញដោយ NAA ជាពិសេសការធ្វើផែនការសកម្មភាព និងពង្រឹងយន្តការនៅថ្នាក់ក្រោមជាតិ ក្នុងការឆ្លើយតបមេរោគអេដស៍ ។<br>- ជំរុញអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវមានកញ្ចប់ថវិកាសម្រាប់ការងារជាពហុវិស័យ រួមទាំងការងារប្រយុទ្ធនឹងជំងឺអេដស៍ | ក្រសួងមហាផ្ទៃ (MoI) |

# ទិសដៅ និងសកម្មភាពអនុវត្តបន្ត (៨)

| ល.រ | ទិសដៅ និងសកម្មភាពចម្បងៗ | ស្ថាប័ន ទទួលខុសត្រូវ |
|---|---|---|
| ៣១ | - បន្តជំរុញដល់អង្គភាពក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានគេហទំព័រផ្សព្វផ្សាយ សារអប់រំទាំងបញ្ហាអេដស៍ និងគ្រឿងញៀន នៅលើគេហទំព័ររបស់ខ្លួន។<br>- បន្តការតាមដានលើសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍តាមរយៈកម្មវិធីអប់រំបញ្ហាអេដស៍ សុខភាពបន្តពូជ សុខភាពផ្លូវភេទ តាមប្រព័ន្ធលេខទូរស័ព្ទខ្លី ៤ខ្ទង់ ដែលបានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍និងទូរគមនាគន៍ និងនិយ័តករទូរគមនាគមន៍កម្ពុជា។<br>- ចូលរួមអន្តរគមន៍តាមរយៈនិយ័តករទូរគមនាគមន៍កម្ពុជា ស្នើទៅក្រុមហ៊ុនទូរស័ព្ទចល័តក្នុងការបញ្ជូនសារអប់រំបញ្ហាអេដស៍ និងគ្រឿងញៀន នាឱកាសបុណ្យជាតិធំៗ។ | ក្រសួងប្រៃសណីយ៍ និងទូរគនាគមន៍ |
| ៣២ | - បន្តផ្សព្វផ្សាយបញ្ហាបង្ការមេរោគអេដស៍តាមរយៈកម្មវិធីនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម នៅទីស្តីការក្រសួងធម្មការ និងសាសនា | ក្រសួងធម្មការ និងសាសនា |
| ៣៣ | - បន្តការគាំទ្រដល់គ្រួសារផ្ទុកមេរោគអេដស៍ដែលមានប័ណ្ណសមធម៌ បានទទួលនូវថវិកាឧបត្ថម្ភពីរាជរដ្ឋាភិបាល (អ្នកមានប័ណ្ណកម្រិត ១ មានចំនួន៦៤៦គ្រួសារ និងកម្រិត ២ មានចំនួន ។<br>- ១៣៨៥គ្រួសារ ។ ចំនួនថវិកាបានបើកក្នុងកំឡុងកូវីដ-១៩ ជូនគ្រួសារដែលផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ សរុបចំនួន១ឮ៣៧៨.៤២០.០០០រៀល ។ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

# ទិសដៅ និងសកម្មភាពអនុវត្តបន្ត (៩)

| ល.រ | ទិសដៅ និងសកម្មភាពចម្បងៗ | ស្ថាប័ន ទទួលខុសត្រូវ |
|---|---|---|
| ៣៤ | - បន្តបញ្ជ្រាបខ្លឹមសារច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរ<br>- បន្តបញ្ជ្រាបខ្លឹមសារច្បាប់ស្តីពី ការបង្ការ និងទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈការផ្សព្វផ្សាយច្បាប់ និងអនុក្រឹត្យ | ក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច |
| ៣៥ | - បន្តធ្វើការអប់រំ និងផ្សព្វផ្សាយស្តីពីការបង្ការមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងសិក្ខាសាលា កិច្ចប្រជុំ និងព្រឹត្តិការណ៍ផ្សេងៗ | ក្រសួងបរិស្ថាន |
| ៣៦ | - បញ្ចូលសកម្មភាពការងារប្រយុទ្ធនឹងជំងឺអេដស៍ និងថែទាំសុខភាពមាតា និងទារកចូលទៅក្នុងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងថាមពល និងប្រេងកាតឆ្នាំ២០២១-២០២៥ ជាផ្លូវការ។<br>- ផ្សព្វផ្សាយពីការងារប្រយុទ្ធជំងឺអេដស៍ក្នុងកិច្ចប្រជុំការងារយេនឌ័រ និងបានណែនាំសមាជិកសមាជិកាគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង។ | ក្រសួងរ៉ែ និងថាមពល |
| ៣៧ | - បន្តផ្សព្វផ្សាយដល់មន្ត្រីរាជការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អំពីការការពារ និងទប់ស្កាត់ការឆ្លងរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍។ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល |

# ទិសដៅ និងសកម្មភាពអនុវត្តបន្ត (១០)

| ល.រ | ទិសដៅ និងសកម្មភាពចម្បងៗ | ស្ថាប័ន ទទួលខុសត្រូវ |
|---|---|---|
| ៣៨ | បន្តផ្សព្វផ្សាយពីការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍ ដល់មន្ត្រីក្រោមឱវាទ។ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ៣៩ | - បន្តធ្វើការបញ្ជ្រាបកម្មវិធីបង្ការអេដស៍ ពេលចុះពង្រឹងការងារបក្សនៅមូលដ្ឋាន និងផ្សព្វផ្សាយនៅតាមបណ្តាស្ថានតំណាងរបស់កម្ពុជានៅបរទេស។ | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| ៤០ | - ធ្វើសមាហរណកម្មផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍បញ្ចូលជាមួយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររយៈពេល ៥ឆ្នាំរបស់ក្រសួង ពី២០១៩-២០២៣ ដើម្បីងាយស្រួលកសាងផែនការថវិកា និងធនធាន។<br>- វគ្គបំប៉នគ្រូបង្គោលអំពីជំងឺអេដស៍ មេរោគអេដស៍ ដល់មន្ត្រីបង្គោលមកពីមន្ទីរ រាជធានីខេត្ត ដើម្បីមានមូលដ្ឋានផ្សព្វផ្សាយបន្តដល់មន្ត្រីក្រោមឱវាទនៅថ្នាក់មូលដ្ឋានត្រូវបានផ្អាកទាំងសកម្មភាព ទាំងកញ្ចប់ថវិកាដែលបានទទួលអនុម័តរួចពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ៤១ | - បន្តផ្សព្វផ្សាយដល់មន្ត្រីរាជការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អំពីការការពារ និងទប់ស្កាត់ការឆ្លងរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍។ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល |

# ទិសដៅ និងសកម្មភាពអនុវត្តបន្ត (១១)

| ល.រ | ទិសដៅ និងសកម្មភាពចម្បងៗ | ស្ថាប័ន ទទួលខុសត្រូវ |
|---|---|---|
| ៤២ | បន្តផ្សព្វផ្សាយដល់មន្ត្រីរាជការ នៃបញ្ញោបក្នុងកិច្ចប្រជុំ សិក្ខាសាលា អំពីការបង្ការទប់ស្កាត់ ការធ្វើតេស្តឈាមរកមេរោគអេដស៍ និងការព្យាបាលជំងឺអេដស៍ | ក្រសួងអភិវឌ្ឍជនបទ |
| ៤៣ | អនុវត្តផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ របស់ក្រសួងសម្រាប់ទិសដៅ ឆ្នាំ២០២៣។ | ក្រសួងមុខងារសាធារណៈ |
| ៤៤ | បន្តការផ្សព្វផ្សាយ អប់រំ ស្តីពីការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅពេលមានការរៀបចំកិច្ចប្រជុំផ្សេងៗ តាមអង្គភាពក្រោមឱវាទក្រសួងកសិកម្ម ពិសេសវិទ្យាស្ថាន និងសាកលវិទ្យាល័យ។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៤៥ | បន្តការចូលរួមយ៉ាងសកម្ម គាំទ្រដល់ការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជា | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

- ក្នុងឆ្នាំ២០២២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានវិភាជន៍ថវិកាសរុបចំនួន៖
  - ប្រាក់រៀល ២៧,៦៧៨,២៨៨,០០០ រៀល
  - ប្រាក់ដុល្លា ១៩,៣៤៦,៩៧១ ដុល្លា

២. តារាងថវិកាលម្អិតសម្រាប់កម្មវិធីអេដស៍ឆ្នាំ២០២២

| បរិយាយ | ២០២២ | | ផ្សេងៗ |
|---|---|---|---|
| | ប្រាក់រៀល | ប្រាក់ដុល្លារ | |
| ១. ថវិកាជាតិ | ២៣,១៩៤,៤០០,០០០ | | |
| - ថ្នាក់ជាតិ | ២២,៨៧៤,៤០០,០០០ | | |
| -អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | ៥,៦៧២,៧០០,០០០ | | |
| -មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ | ១៧,២០១,៧០០,០០០ | | |
| • ថ្នាក់ក្រោមជាតិ | ៣២០,០០០,០០០ | | |
| -រាជធានីភ្នំពេញ | ៨០,០០០,០០០ | | |
| -បាត់ដំបង | ៨០,០០០,០០០ | | |
| -បន្ទាយមានជ័យ | ៨០,០០០,០០០ | | |
| -សៀមរាប | ៨០,០០០,០០០ | | |
| ២.ហិរញ្ញប្បទានឥតសំណងសម្រាប់កម្មវិធីអេដស៍ឆ្នាំ២០២២ | | ១៩,៣៤៦,៩៧១ | |
| -ថវិកាសម្រាប់កម្មវិធីអេដស៍ (HIV) ឆ្នាំ២០២២ | | ១៨,៦៧០,០៦៨.៤៧ | |
| -យន្តការ C19 Response Mechanism (C19-RM) ឆ្នាំ២០២២ | | ៦៧៦,៩០២.៥៣ | |
| ៣. អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម | ៤,៤៨៣,៨៨៨,០០០ | | |
| -៩ខែ ដើមឆ្នាំ២០២២ ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ មានចំនួន ២០៤៦គ្រួសារ | ៣,៣៦២,៩១៦,០០០ | | |
| -គ្រោងចំណាយសម្រាប់រយៈពេល ៣ខែ ចុងក្រោយ | ១,១២០,៩៧២,០០០ | | |
| សរុប = (១) + (៣) | ២៧,៦៧៨,២៨៨,០០០ | ១៩,៣៤៦,៩៧១ | |



# End Inequalities,

## End AIDS. End Pandemics.

# សូមអរគុណ!